# សុន្ទរកថា
# ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងឧទ្ទេសនាម «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»
# និង «វិធានការគន្លឹះរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា»
# ក្នុងអង្គប្រជុំលើកដំបូង នៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧ នៃរដ្ឋសភា
# នៅ វិមានសន្តិភាព
# ថ្ងៃ ព្រហស្បតិ៍, ៨ កើត, ខែ ស្រាពណ៍, ឆ្នាំ ថោះ, បញ្ចស័ក, ព.ស. ២៥៦៧
# ត្រូវនឹងថ្ងៃទី ២៤ ខែ សីហា គ.ស. ២០២៣

*****+*****

**ឯកឧត្តម, លោកជំទាវ, ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, សមាជិក-សមាជិកា នៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល ជាទីមេត្រី !**

ថ្ងៃនេះ ជាថ្ងៃប្រវត្តិសាស្ត្រ ដែលខ្ញុំមានកិត្តិយស និងសេចក្ដីរីករាយបំផុត សូមយកឱកាសនៃអង្គប្រជុំលើកដំបូងនៃគណៈរដ្ឋមន្ត្រី របស់យើងនាពេលនេះ ប្រកាសជូនជនរួមជាតិកម្ពុជា និងតួអង្គពាក់ព័ន្ធទាំងអស់ជ្រាប អំពីអាទិភាពគោលនយោបាយសំខាន់ៗ និងការប្ដេជ្ញាចិត្តយ៉ាងមុតមាំឥតងាករេរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ក្នុងការបន្តអនុវត្តនូវកម្មវិធីកែទម្រង់សំខាន់ៗ លើគ្រប់វិស័យ ក្នុងគោលដៅបម្រើឧត្តមប្រយោជន៍ជាតិ និង ឆ្លើយតបទៅនឹងសំណូមពរ និង សេចក្ដីត្រូវការរបស់ប្រជាជន។

ផ្អែកលើ «កម្មវិធីនយោបាយ សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨» របស់គណបក្សប្រជាជនកម្ពុជា ដែលប្រជាពលរដ្ឋទូទាំងប្រទេសបានផ្ដល់ការគាំទ្រភ្លូកទឹកភ្លូកដី នៅក្នុងការបោះឆ្នោត នាថ្ងៃទី ២៣ ខែ កក្កដា កន្លងទៅនេះ, រាជរដ្ឋាភិបាលបានរៀបចំ «**កម្មវិធីនយោបាយ**» របស់ខ្លួន សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា។ ឈរលើមូលដ្ឋាននៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ នៃលទ្ធផលការងារដែលបានអនុវត្តក្នុងនីតិកាលមុនៗ ក៏ដូចជាបរិការណ៍ជាតិ និង អន្តរជាតិ នាបច្ចុប្បន្ន និង ទៅអនាគត ព្រមទាំងដោយយកចិត្តទុកដាក់ឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន, «**កម្មវិធីនយោបាយ**» នេះ បានកំណត់ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រ, គោលនយោបាយចម្បងៗជាអាទិភាព, គោលនយោបាយអភិវឌ្ឍតាមវិស័យ និង កម្មវិធីគោលនយោបាយជាអាទិភាព ដែលត្រូវចាប់

អនុវត្តពីឆ្នាំ ២០២៣ តទៅ, ដែលជាក្របខ័ណ្ឌសម្រាប់តម្រង់ទិសការងាររបស់រាជរដ្ឋាភិបាល ក្នុងការបន្តបំពេញបេសកកម្មបម្រើជាតិ និង ប្រជាជន នៅក្នុងនីតិកាលទី ៧ នេះ ។ ក្នុងនាមជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣, ខ្ញុំបាន ដាក់បង្ហាញ «**កម្មវិធីនយោបាយ**» នេះ ជូនអង្គរដ្ឋសភា, និង ជូនដល់ប្រជាជនកម្ពុជា ទូទាំងប្រទេស តាមរយៈរដ្ឋសភា ។

**ឈរលើមូលដ្ឋាននៃ «កម្មវិធីនយោបាយ» នេះ, រាជរដ្ឋាភិបាលបានរៀបចំ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាននូវ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សម្រាប់ជំរុញអនុវត្ត ប្រកបដោយប្រសិទ្ធភាពនូវ «កម្មវិធីនយោបាយ» របស់ខ្លួន និង ជាមគ្គុទេសក៍សម្រាប់ តម្រង់សកម្មភាព របស់គ្រប់តួអង្គទាំងអស់** ក្នុងគោលដៅ, ម៉្យាង, បន្តរក្សាឱ្យបានរឹងមាំនូវ ចលនការនៃសុខសន្តិភាព ក៏ដូចជាពូនជ្រំ និង ពង្រឹងសមិទ្ធផលនៃកិច្ចអភិវឌ្ឍដែលសម្រេច បាននាពេលកន្លងមក; និងម៉្យាងទៀត, កសាង និងពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ជំរុញសម្ទុះនៃ ការអភិវឌ្ឍប្រទេសជាតិ ក្នុងរយៈពេលមធ្យម និងវែងទៅមុខ តាមរយៈការកែទម្រង់មុតស្រួច លើគ្រប់វិស័យ ។ ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ ប្រកាសដាក់ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទី ១ របស់យើង, ក៏ដូចជា ជូនដៃគូ អភិវឌ្ឍន៍ និង គ្រប់តួអង្គពាក់ព័ន្ធ ព្រមទាំងប្រជាពលរដ្ឋខ្មែរនៅគ្រប់ទិសទី, ដើម្បីជ្រាប និងរួម សហការគ្នាជាធ្លុងមួយ ក្នុងការជំរុញអនុវត្តឱ្យសម្រេចជោគជ័យ តាមការទន្ទឹងចង់បានរបស់ ប្រជាជនកម្ពុជាដែលជាម្ចាស់ឆ្នោត ។

**ដោយសារ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ វែង, ខ្ញុំនឹងមិនអាន អត្ថបទនៃ ឯកសារនេះទាំងស្រុង នោះទេ ។ ប៉ុន្តែ ខ្ញុំនឹងឧទ្ទេសនាមដោយសង្ខេបអំពីខ្លឹមសារ សំខាន់ៗ នៃ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ នេះ។** យ៉ាងណាក៏ដោយ, អត្ថបទទាំងស្រុងនៃយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំចងក្រងជាសៀវភៅ ដែលមានម្ខាងជា ភាសាខ្មែរ, និងម្ខាងទៀត ជាភាសាអង់គ្លេស, ហើយត្រូវបានចែកជូនដល់សមាជិក-សមាជិកា នៃអង្គប្រជុំរបស់យើង ដូចមាននៅចំពោះមុខ ឯកឧត្តម និង លោកជំទាវ ទាំងអស់គ្នាស្រាប់ ។ បន្ថែមលើនេះ, ក្រោយពីកិច្ចប្រជុំនេះទៅ, ខ្ញុំសូមស្នើឱ្យទីស្តីការគណៈរដ្ឋមន្ត្រី យកឯកសារនេះ ទៅរៀបចំដាក់ផ្សព្វផ្សាយជាសាធារណៈ នៅក្នុងគេហទំព័រផ្លូវការរបស់រាជរដ្ឋាភិបាល ដើម្បីផ្តល់ ភាពងាយស្រួលដល់គ្រប់តួអង្គពាក់ព័ន្ធ និង សាធារណជនទូទៅ អាចទាញយកក្នុងទម្រង់ទន់

(Soft copy) ឬ បោះពុម្ពចេញជាទម្រង់រឹង សម្រាប់ប្រើប្រាស់តាមសេចក្តីត្រូវការចាំបាច់ ។ ជាមួយគ្នានេះដែរ, ខ្ញុំស្នើឱ្យឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រៀមរៀបចំបោះពុម្ពឯកសារនេះ ជាសៀវភៅបន្ថែមទៀត ដើម្បីចែកជូនដល់ក្រសួង-ស្ថាប័ន និង ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ តាមសេចក្តីត្រូវការចាំបាច់ជាយថាហេតុ ។

ជាមួយនឹងការគូសបញ្ជាក់ខាងលើនេះ, ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមធ្វើការឧទ្ទេសនាមដោយសង្ខេប អំពីខ្លឹមសារសំខាន់ៗនៃ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» ដូចតទៅ៖

## ១. សាវតារ

**ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ, បន្ទាប់ពីការសម្រេចបាននូវសុខសន្តិភាពពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ នយោបាយឈ្នះ-ឈ្នះ របស់ សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន, រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យ នូវយុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល,** ដោយសម្រេចបាននូវសមិទ្ធផលធំៗ លើគ្រប់វិស័យ, ទាំងនយោបាយ, សង្គម, និង សេដ្ឋកិច្ច, ដែលនាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត ។

**ជាក់ស្តែង, កម្ពុជាដែលពីមុនធ្លាប់ត្រូវបានហែកហួរដោយសង្គ្រាម និង ធ្លាប់តែល្បីថាជាវាលពិឃាត, ជាតំបន់អសន្តិសុខ និងជាចម្ការមីន ដែលគេភ័យខ្លាចគ្រប់គ្នា, បានក្លាយទៅជារដ្ឋអធិបតេយ្យ និងឯករាជ្យ ដែលមានសន្តិភាព, មាននីតិរដ្ឋ និងស្ថិរភាពនយោបាយស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស, និងមាន ព្រះមហាក្សត្រ ជាទីគោរពសក្ការៈ គង់ប្រថាប់ជាម្លប់** ។ កម្ពុជាដែលពីមុនធ្លាប់តែត្រូវបានហ៊ុមព័ទ្ធ និង ឯកោ, ទាំងនយោបាយ និង សេដ្ឋកិច្ច, ឥឡូវមានសមាហរណកម្មពេញលេញនៅក្នុងរចនាសម្ព័ន្ធ និងនិម្មាបនកម្មតំបន់ និងសកល, និងបានដើរតួយ៉ាងសំខាន់ក្នុងការរក្សាសណ្តាប់ធ្នាប់ និងសន្តិភាពនៃសកលលោក ។ ប្រជាជនកម្ពុជារាប់លាននាក់ បានចាកផុតពីភាពក្រីក្រ និងកំពុងរស់នៅជាមួយនឹងជីវភាពសមរម្យ, មានចំណេះដឹង, មានសុខុមាលភាពកាន់តែប្រសើរ ហើយអាយុកាលសង្ឃឹមរស់ជាមធ្យម បានកើនឡើងគួរឱ្យកត់សម្គាល់ ។

**មូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ក៏បានប្រែប្រួលពីប្រទេសដែលពឹងផ្អែកស្ទើរទាំងស្រុងទៅលើវិស័យកសិកម្មបែបប្រពៃណី ទៅជាប្រទេសមានមូលដ្ឋានសេដ្ឋកិច្ចទូលាយ និងរឹងមាំ ដែលអាចចាប់យកឧស្សាហកម្មថ្មីៗ និងមានតម្លៃបន្ថែមខ្ពស់** ។ កម្ពុជាដែលពីមុនមានវិបត្តិខ្វះសាច់ប្រាក់រ៉ាំរ៉ៃ និងត្រូវពឹងផ្អែកស្ទើរទាំងស្រុងទៅលើជំនួយបរទេស ទើបអាចរស់រានបាន,

ឥឡូវបានក្លាយជាប្រទេសមានស្វ័យភាព និងភាពម្ចាស់ការពេញលេញផ្នែកហិរញ្ញវត្ថុ នៅក្នុងការកំណត់ជោគវាសនា និងអនាគតរបស់ខ្លួន។ ដួងព្រលឹងនៃមរតកសិល្បៈវប្បធម៌ខ្មែរ, ទាំងរូបី និងអរូបី, ដែលធ្លាប់ត្រូវបានលួច, បាត់បង់ ឬខូចខាតដោយសារសង្គ្រាម, ឥឡូវត្រូវបានស្តារឱ្យរស់ និង លើកស្ទួយឡើងវិញ ជាបេតិកភណ្ឌជាតិ និងបេតិកភណ្ឌពិភពលោក ក៏ដូចជាត្រូវបានទទួលស្គាល់ និងជូនត្រឡប់មកកាន់មាតុភូមិកំណើតវិញ។ បន្ថែមលើនេះ, ស្នាដៃធំៗ និង ថ្មីៗ របស់រាជរដ្ឋាភិបាលរួមមានការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, ជោគជ័យនៃការទទួលធ្វើជាប្រធានអាស៊ានជាលើកទី ៣ ក្នុងប្រវត្តិសាស្ត្រ ដោយបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដោយផ្ទាល់ក្រោយពីវិបត្តិជំងឺកូវីដ-១៩, ព្រមទាំងជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ជាទឡ្ហីករណ៍មិនអាចប្រកែកបានមួយចំនួនទៀត នៃការរីក-ចម្រើនប្រកបដោយមោទនភាពរបស់កម្ពុជា ។

**ជារួម, យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល បានបំពេញតួនាទីយ៉ាងប្រសើរ, ជារបៀបវារៈគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា** ដែលបានផ្តល់នូវក្របខ័ណ្ឌរួម សម្រាប់ការកសាងស្ថាប័នរដ្ឋមួយ រឹងមាំ និងឯករាជ្យ, ដែលប្រព័ន្ធអភិបាលកិច្ច ត្រូវបានធ្វើទំនើបកម្មជាប្រចាំ ឱ្យកាន់តែគ្រប់ជ្រុងជ្រោយ, មានភាពធន់ និងមានប្រសិទ្ធភាព; និង សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងល្បឿនខ្ពស់ ដែលត្រូវបានទទួលស្គាល់, ទាំងក្នុងតំបន់ និងសកលលោក; ជាពិសេស សម្រាប់ការប្រែក្លាយកម្ពុជាជាប្រទេសចំណូលមធ្យមកម្រិតទាប ក្នុងរយៈពេលដ៏ខ្លី ជាមួយកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រយ៉ាងហ័ស, ព្រមទាំងការធ្វើសមាហរណកម្មដោយជោគជ័យ ទៅក្នុងតំបន់ និងសកលលោក ។

**ជោគជ័យដ៏ធំធេង និងត្រចះត្រចង់ខាងលើ បានមកពីកិច្ចខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់របស់រាជរដ្ឋាភិបាល ដែលប្រកាន់ខ្ជាប់នូវការតម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ, ព្រមទាំងការអនុវត្តការកែទម្រង់ជាប្រចាំ ដោយមានការគាំទ្រពីគ្រប់ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធ, ក៏ដូចជាការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់** ។ កិច្ចប្រឹងប្រែង និងការចូលរួមទាំងនេះ ក៏ជាមូលដ្ឋានដ៏រឹងមាំ ដែលអនុញ្ញាតឱ្យកម្ពុជារក្សាបានគត់មត់នូវសុខសន្តិភាព និងស្ថិរភាពនយោបាយ, ហើយលើសពីនេះ ពង្រឹងភាពជាម្ចាស់លើជោគវាសនាប្រទេសជាតិ ព្រមទាំងលើកកម្ពស់វិបុលភាពជូនប្រជាជន ជាបន្តបន្ទាប់មកទល់បច្ចុប្បន្ន ។

**ពេលនេះ, ដំណើរការកសាងជាតិរបស់កម្ពុជា បានឈានដល់ដំណាក់កាលថ្មីមួយ នៅក្នុងបរិការណ៍នៃពិភពលោក ដែលកាន់តែប្រែប្រួល លំបាក និងមិនប្រាកដប្រជា** ។ កម្ពុជាត្រូវប្រឈមនឹងបញ្ហាថ្មី ក្នុងអន្តរកាលឆ្ពោះទៅសម្រេចឋានៈជាប្រទេសមានចំណូលខ្ពស់ និងត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាននូវគោលនយោបាយសមស្រប និងសមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និងការទទួលខុសត្រូវ ។

**ឈរលើមូលដ្ឋាននេះ, ការគិតគូរអំពីរបៀបវារៈអភិវឌ្ឍសង្គម-សេដ្ឋកិច្ច សម្រាប់ដំណាក់-កាលបន្ទាប់ គឺជាការសម្លឹងឆ្ពោះទៅសម្រេចបាននូវ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ដោយផ្អែកលើបទពិសោធន៍ និងសមិទ្ធផល ២៥ ឆ្នាំកន្លងមក និងការវាយតម្លៃប្រមើលសម្រាប់ ២៥ ឆ្នាំទៅមុខ, ហើយរៀបចំឡើងនូវយុទ្ធសាស្ត្រ សម្រាប់អនុវត្ត ជាដំណាក់កាលៗ** ។ កន្លងមក, **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** អាចត្រូវបានចាត់ទុកជា **ដំណាក់កាលមួយនៃការកសាងជាតិ** ដោយផ្តោតជាសំខាន់ លើការស្តារ និងការកសាងប្រទេស ដែលទើបងើបចេញពីសង្គ្រាម; ការរក្សាសុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម; ការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធ និងនិម្មាបនកម្មតំបន់ និងសកល; ការអភិវឌ្ឍ និងការរក្សាស្ថិរភាពសេដ្ឋកិច្ច និង សង្គម; និងការប្រឹងប្រែងលើកកម្ពស់ជីវភាពប្រជាជន។ សម្រាប់រយៈពេល ២៥ ឆ្នាំបន្ទាប់ ដែលជាវដ្តថ្មី, **<u>កម្ពុជាមានមហិច្ឆតាចង់លើកស្ទួយមោទនភាពជាតិ ឱ្យឈានកាន់តែខ្ពស់ឡើង ដូចសម័យអង្គរ តាមរយៈការកសាងជាតិមួយឱ្យរឹងមាំ, រស់រវើក, រុងរឿង និងមានវិបុលភាព ក្លាយជាប្រទេសមានចំណូលខ្ពស់ នៅត្រឹមឆ្នាំ២០៥០</u>**។

## ២. ភាពចាំបាច់នៃយុទ្ធសាស្ត្របញ្ចកោណ

**ឈរលើមូលដ្ឋាននៃសមិទ្ធផល ដែលសម្រេចបានក្នុងរយៈពេល ២៥ ឆ្នាំ កន្លងមក និងការពិនិត្យវាយតម្លៃនិន្នាការតំបន់ និងសកល ជាមួយនឹងការប្រមើលទៅមុខ ២៥ ឆ្នាំ សំដៅឆ្លើយតបនឹងបំណងប្រាថ្នាប្រជាជន ឆ្ពោះទៅសម្រេចបាននូវ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០, រាជរដ្ឋាភិបាលដាក់ចេញ "យុទ្ធសាស្ត្របញ្ចកោណ" ដើម្បីជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ, ធានាសមធម៌, បង្កើនប្រសិទ្ធភាព និង រក្សាចីរភាព** ។ ជារួម, **យុទ្ធសាស្ត្របញ្ចកោណ** គឺជាយុទ្ធសាស្ត្រសម្លឹងទៅមុខ សម្រាប់រយៈពេល ២៥ ឆ្នាំ ដែលត្រូវបានគិតគូរ ដាក់ចេញ និងអនុវត្តជា ៥ ដំណាក់កាល បន្តបន្ទាប់ និងត្រូវបានតម្រង់ និងសម្របសម្រួលទៅតាម **កម្មវិធី**

**នយោបាយរបស់រាជរដ្ឋាភិបាល** នៃនីតិកាលនីមួយៗ នៃរដ្ឋសភា។ ដំណាក់កាលនីមួយៗ នឹងត្រូវបានកែសម្រួល ដោយផ្អែកលើបរិការណ៍ជាក់ស្តែង នៅក្នុងប្រទេស, តំបន់ និងពិភពលោក ព្រមទាំងបទពិសោធន៍នៃការអនុវត្តពីដំណាក់កាលមុនៗ ដោយសម្លឹងទៅមុខ ឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅនៃការកសាងជាតិស្របតាម **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

**ក្នុងក្របខណ្ឌនៃការគិតគូរជារួមខាងលើ, សម្រាប់រយៈពេល ៥ ឆ្នាំដំបូង ក្នុងនីតិកាលទី ៧ នៃរដ្ឋសភានេះ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយយោងលើភាពចាំបាច់ជាក់ស្តែង នៅក្នុងទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម ៖**

១. *ភាពចាំបាច់* **ក្នុងការបន្តពង្រឹង និងពង្រីកសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបាននៅក្នុងនីតិកាលកន្លងមក នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** តាមរយៈ ការការពារឱ្យបានដាច់ខាត និង ការបន្តពង្រឹងនូវសុខសន្តិភាព, ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម; ការពង្រឹងការគោរពច្បាប់ និងវិធាននៃច្បាប់, ការលើកស្ទួយនីតិរដ្ឋ, សិទ្ធិសេរីភាព, សេចក្តីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស; និង ការអនុវត្តវិធានការជាក់ស្តែងនានា សំដៅលើកកម្ពស់កម្រិតជីវភាព និង សុខុមាលភាពប្រជាជន, ជាពិសេស ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃអភិបាលកិច្ច, ស្ថាប័ន និង យុត្តិធម៌សង្គម ព្រមទាំងការពង្រឹងភាពស្អាតស្អំ និង គុណភាពសេវាសាធារណៈ ។

២. *ភាពចាំបាច់* **ក្នុងការបន្តកែទម្រង់ស្ថាប័ន និងអភិបាលកិច្ច ឱ្យសម្រេចបាននូវរដ្ឋបាលសាធារណៈមួយ ដែលមានសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ ហើយបំពេញការងារនៅក្នុង "ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ"** ព្រមទាំងធានាបាននូវប្រសិទ្ធភាពខ្ពស់ នៅក្នុងគ្រប់ទិដ្ឋភាពនៃកិច្ចប្រតិបត្តិការរបស់ខ្លួន, ទាំងការដឹកនាំ, ការសម្របសម្រួល, ការត្រួតពិនិត្យ និង ការវាយតម្លៃ លើការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រនានា នៅក្នុងបរិការណ៍នៃការវិវត្តប្រែប្រួលយ៉ាងរហ័សនៃសភាពការណ៍សង្គម-សេដ្ឋកិច្ច, ទាំងក្នុង និង ក្រៅប្រទេស ។

៣. *ភាពចាំបាច់* **ក្នុងការបន្តកសាង និង ពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដោយផ្តោតជាសំខាន់លើ ការកសាងមូលធនមនុស្សរឹងមាំ**, ពិសេស តាមរយៈការកែទម្រង់វិស័យអប់រំ និង វិស័យសុខាភិបាល; ការបង្កើនផលិតភាពសេដ្ឋកិច្ច; ការ-លើកកម្ពស់ចំណេះដឹងរបស់ប្រជាជន និង សមត្ថភាពជំនាញរបស់ពលករ; ការពង្រឹងអភិបាល-កិច្ចវិស័យឯកជន និង ធុរកិច្ច; និង ការលើកកម្ពស់ការតភ្ជាប់ ព្រមទាំងការជំរុញអភិវឌ្ឍហេដ្ឋា-

របនាសម្ព័ន្ធគ្រប់ប្រភេទ, ទាំងរឹង និង ទន់, រួមបញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលផង, ដើម្បីឈានទៅបង្កើតឡើងនូវម៉ូដែលថ្មីនៃកំណើន ដែលផ្អែកលើជំនាញ, បច្ចេកវិទ្យា និងនវានុវត្តន៍ ។

**៤. ភាពចាំបាច់ ក្នុងការបង្កើនការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជា និង ក្នុងការកសាងភាពធន់ទៅនឹងការប្រែប្រួលនៃកត្តាសង្គម-សេដ្ឋកិច្ច និង កត្តាបរិស្ថានធម្មជាតិ** ដើម្បីពង្រឹងមូលដ្ឋានកំណើនសេដ្ឋកិច្ច និង ធានាចីរភាពនៃកំណើនខ្ពស់ តាម-រយៈការបង្កើនតម្លៃបន្ថែម ក្នុងវិស័យចន្ទល់កំណើនសេដ្ឋកិច្ចដែលមានស្រាប់ និង វិស័យផ្សេងទៀតដែលកម្ពុជាមានសក្តានុពល; ការជំរុញការវិនិយោគក្នុងវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម; ការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និង ឧស្សាហូបនីយកម្ម; ការលើកកម្ពស់ការប្រកួតប្រជែងស្មើភាព និង ការលើកស្ទួយភាពប្រកួតប្រជែងរបស់កម្ពុជា; ការកសាងភាពធន់ទល់នឹងគ្រោះអាសន្ន និង វិបត្តិនានា; ព្រមទាំងការលើកកម្ពស់ទំនាក់ទំនងអន្តរជាតិ និង ការទូត និង ការធ្វើសមាហរណកម្មស៊ីជម្រៅ ទៅក្នុង តំបន់ និង សកលលោក សំដៅទាញយកផលប្រយោជន៍សេដ្ឋកិច្ច និង សង្គម ឱ្យបានជាអតិបរមាជូនប្រទេសជាតិ ។

**៥. ភាពចាំបាច់ ក្នុងការដាក់ចេញ នូវ របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយមួយ នៃ "កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា"** ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ការបន្តដំណើរឈានទៅសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**។

## ៣. បេសកកម្មនៃយុទ្ធសាស្ត្រ និង អភិក្រមក្នុងការអនុវត្ត

**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព មានបេសកកម្មជាប្រវត្តិសាស្ត្រ ចម្បងពីរ គឺ ៖ ទីមួយ, រក្សា និង ថែបំប៉នសុខសន្តិភាព** ដែលសម្រេចបានមកដោយលំបាក ជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាន, និងពូនជ្រំចលនការ នៃ កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍ ជារួម; និង **ទីពីរ, កសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ**, ដោយឆ្លងកាត់បង្គោលចរនៃការ-ប្រែក្លាយខ្លួន ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០, ឆ្ពោះទៅសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** តាមរយៈ **ការកសាងភាពធន់រឹងមាំនៃវិស័យទាំង ៥** ពោលគឺ : **ភាពធន់នៃវិស័យសាធារណៈ, ភាពធន់នៃវិស័យសេដ្ឋកិច្ច, ភាពធន់នៃវិស័យហិរញ្ញវត្ថុ, ភាពធន់នៃវិស័យមូលធនមនុស្ស និង សង្គម, និង ភាពធន់នៃវិស័យបរិស្ថាន និងក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ**។

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ត្រូវបានដាក់ឱ្យអនុវត្ត ស្របតាមអភិក្រម "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ" ដែលក្រសួង-ស្ថាប័នទាំងអស់ នៅក្រោមរចនាសម្ព័ន្ធរាជរដ្ឋាភិបាល, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ធ្វើការនៅក្នុងកិច្ចសហការ និងការសម្រុះសម្រួលរស់រវើក ប្រកបដោយសហថាមពល និងដោយបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំង ដោយបត់បែនតាមការប្រែប្រួលនៃបរិការណ៍ជាក់ស្តែង ដើម្បីសម្រេចបានគោលដៅអាទិភាពដែលត្រូវបានដាក់ចេញ។

## ៤. បាវចនា, គោលដៅយុទ្ធសាស្ត្រ និងអាទិភាពគន្លឹះនៃយុទ្ធសាស្ត្រ

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ មាន **បាវចនា ៥, គោលដៅយុទ្ធសាស្ត្រ ៥ និង អាទិភាពគន្លឹះ ៥** ។

**បាវចនា ៥** រួមមាន ៖ **កំណើន**, **ការងារ**, **សមធម៌**, **ប្រសិទ្ធភាព**, **និរន្តរភាព** ។

**គោលដៅយុទ្ធសាស្ត្រ ៥** រួមមាន ៖

(១). **ធានាឱ្យបានកំណើនសេដ្ឋកិច្ច** ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា;

(២). **បង្កើតការងារឱ្យបានកាន់តែច្រើន**, ទាំងបរិមាណ និង គុណភាព, ជូនដល់ប្រជាជនកម្ពុជា, ជាពិសេស សម្រាប់យុវជន;

(៣). **សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ** ក្នុងអត្រាទាបជាង ១០% និងបន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រ ឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា;

(៤). **បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន**, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជា បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន និង បន្តកិច្ចប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច, ការវិនិយោគ និង ពាណិជ្ជកម្ម; និង

(៥). **ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច** និងកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ជាមួយនឹង **បាវចនា ៥** និង **គោលដៅយុទ្ធសាស្ត្រ ៥** ដូចបានគូសរំលេចខាងលើ, រាជរដ្ឋាភិបាលសម្រេចកំណត់យកនូវ **អាទិភាពគន្លឹះ ចំនួន ៥** សម្រាប់ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** គឺ : **មនុស្ស**, **ផ្លូវ**, **ទឹក**, **ភ្លើង** និង **បច្ចេកវិទ្យា** ដែល

ត្រូវបានឆ្លុះបញ្ចាំងជាចម្បង តាមរយៈ **បញ្ចកោណយុទ្ធសាស្ត្រ** នៅក្នុងរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រទាំងមូល ។

## ៥. រចនាសម្ព័ន្ធ និង ខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រ

**ជារួម, រចនាសម្ព័ន្ធនៃ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ មាន ៖ (១). ស្នូលនៃយុទ្ធសាស្ត្រ** គឺៈ ការកែទម្រង់ និង ការពង្រឹង អភិបាលកិច្ច; (២). **បរិស្ថានគ្របដណ្តប់** សម្រាប់ធានាបរិយាកាសអំណោយផល ដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល; និង (៣). **បញ្ចកោណយុទ្ធសាស្ត្រ ទាំង ៥** សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និង វឌ្ឍនភាពសង្គម ។

**ស្នូលនៃយុទ្ធសាស្ត្រ, បរិស្ថានគ្របដណ្តប់ និង បញ្ចកោណយុទ្ធសាស្ត្រ ទាំងអស់នេះប្រៀបបានទៅនឹងអនុគមន៍ផលិតកម្ម ដែលការអនុវត្តវិធានការប្រទាក់ក្រឡាគ្នា នឹងនាំទៅដល់ការបង្កើនផលិតភាពសរុបនៃសេដ្ឋកិច្ច, ការបង្កើនផលិតភាពនៃកម្លាំងពលកម្ម និងការបង្កើនការវិនិយោគ ក៏ដូចជាប្រសិទ្ធភាពនៃការវិនិយោគលើមូលធនសេដ្ឋកិច្ច** ។ ផលិតភាពសរុប នឹងត្រូវបានបង្កើន តាមរយៈសម្ព័ន្ធនៃវិធានការ ដែលត្រូវបានរៀបចំឡើង, ម្យ៉ាង, នៅក្នុង **ស្នូលនៃយុទ្ធសាស្ត្រ** ដោយផ្តោតលើ ការកែទម្រង់អភិបាលកិច្ច និង ការពង្រឹងសមត្ថភាពស្ថាប័ន; និងម្យ៉ាងទៀត, នៅក្នុង **បរិស្ថានគ្របដណ្តប់** ដោយផ្តោតលើការបង្កើតបរិយាកាសអំណោយផល សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ចំណែកផលិតភាពផ្នែកពលកម្ម និង ផ្នែកមូលធន នឹងត្រូវបានបង្កើនតាមរយៈ **បញ្ចកោណយុទ្ធសាស្ត្រ ចំនួន ៥** រួមមាន ៖ (១). **ការអភិវឌ្ឍមូលធនមនុស្ស**; (២). **ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង**; (៣). **ការអភិវឌ្ឍវិស័យឯកជន និងការងារ**; (៤). **ការអភិវឌ្ឍ ប្រកបដោយភាពធន់, ចីរភាព និងបរិយាប័ន្ន**; និង (៥). **ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល** ។

**ស្នូលនៃយុទ្ធសាស្ត្រ ផ្តោតលើអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ** តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋ ខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និង រដ្ឋបាល ក្នុងការដឹកនាំ, ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការប្រទេសជាតិ, ពិសេស ការធានានិរន្តរភាពនៃតួនាទី និង ដំណើរការរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍ប្រជាជនព្រមជាមួយនឹងការកសាងជាតិ និង ការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន និងចីរភាព ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបន្តផ្តោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ ៖

(១). **ការពង្រឹង និងការកែទម្រង់ស្ថាប័ន** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការកសាងរដ្ឋបាលសាធារណៈ ដែលមានសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ប្រជាជន;

(២). **ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព, ជំនាញ, ឆន្ទៈម្ចាស់ការ និង ក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតួនាទី និង ការទទួលខុសត្រូវ;

(៣). **ការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការលើកកម្ពស់ និងការពង្រឹង ភាពស្អាតស្អំ ភាពសុចរិត និងជំនឿទុកចិត្ត ចំពោះរដ្ឋបាលសាធារណៈ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយ ប្រសិទ្ធភាព បរិយាប័ន្ន និងចីរភាព;

(៤). **ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌ក្នុងសង្គម, និង ការពង្រឹងជំនឿទុកចិត្តពីសាធារណជនមកលើវិស័យយុត្តិធម៌; និង

(៥). **ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការពង្រឹងជំនឿទុកចិត្តរបស់តួអង្គពាក់ព័ន្ធ មកលើវិស័យឯកជន និងធុរកិច្ច តាមរយៈការជំរុញឱ្យមានអភិបាលកិច្ចល្អ ក្នុងវិស័យឯកជន និងធុរកិច្ច ។

**បរិស្ថានគ្រប់ដណ្ដប់ កំណត់នូវក្របខ័ណ្ឌពេញលេញ និងគ្រប់ជ្រុងជ្រោយ** ដើម្បីធានាការសម្រេចបាន នូវអាទិភាពគោលនយោបាយនៃ **យុទ្ធសាស្ត្រ**។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបន្តផ្តោតលើកិច្ចការអាទិភាពចំនួន ៥ គឺ៖

(១). **ការបន្តពង្រឹង សន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ដែលកត្តាទាំងនេះ ជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រទេសជាតិ;

(២). **ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ, ផ្អែកលើច្បាប់ និងឈ្លាសវៃ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការបន្តពង្រឹងការអនុវត្តនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់ ក្នុងកិច្ចការពារ និង ក្នុងការជំរុញបង្កើនផលប្រយោជន៍ស្នូលរបស់ជាតិ, និងការកសាងមិត្តភាព និង កិច្ចសហប្រតិបត្តិការល្អ ជាមួយប្រទេសទាំងអស់នៅលើសកលលោក

និង អង្គការអន្តរជាតិនានា, ព្រមទាំងការចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុ សន្តិភាព ស្ថិរភាព សន្តិសុខ និង វិបុលភាព ក្នុងតំបន់ និង សកលលោក;

(៣). **ការធានាបាននូវស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយ បរិយាប័ន្ន, ភាពធន់ និង ចីរភាព;

(៤). **ការបន្តកសាងភាពជាដៃគូ ប្រកបដោយ បរិយាប័ន្ន និងស័ក្តិសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** ដែលជាកិច្ចការចាំបាច់ដ៏សំខាន់មួយទៀត សម្រាប់បង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន, ភាពធន់ និង ចីរភាព; និង

(៥). **ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅ ទៅក្នុង តំបន់ និងសកលលោក** ដែលផ្តោតលើការបង្កើតកាលានុវត្តភាព ក្នុងការជំរុញ និង ការគាំទ្រ ពាណិជ្ជកម្មអន្តរជាតិ និង ការទាក់-ទាញការវិនិយោគ, ក៏ដូចជា ការចូលរួមកាន់តែជ្រៅទៅក្នុងខ្សែច្រវាក់តម្លៃ និង ការផ្គត់ផ្គង់ នៃតំបន់ និង ជាសកល សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និង ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព។

**បញ្ចកោណទី ១៖ ការអភិវឌ្ឍមូលធនមនុស្ស ដែលក្នុងនេះ រាជរដ្ឋាភិបាលបន្តផ្តោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ៖**

(១). **ការពង្រឹងគុណភាព វិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការបង្កើតបរិយាកាសល្អ សម្រាប់ការអប់រំ និង ការបណ្តុះ-បណ្តាល ប្រកបដោយគុណភាព និង ជំនាញខ្ពស់ តាមរយៈ ការពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា, ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រប់កម្រិត, ការបង្កើនគុណភាព និង ការចូលរៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និង គណិតវិទ្យា (STEAM), និង ការពង្រឹងការអប់រំកាយ និងកីឡា;

(២). **ការបណ្តុះបណ្តាលជំនាញបច្ចេកទេស** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការធ្វើបរិវត្តកម្មការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ; ការបង្កើនការចុះឈ្មោះចូលរៀន; ការរៀបចំជំនាញឡើងវិញ និង ការបង្កើនជំនាញ (Reskilling and Upskilling); ការពង្រឹងប្រព័ន្ធអេកូឡូស៊ីអភិវឌ្ឍជំនាញ; ការដោះស្រាយបញ្ហានៃភាពមិនស៊ីសង្វាក់គ្នារវាងការបណ្តុះបណ្តាល និង តម្រូវការ, ទាំងប្រភេទ និង គុណភាពជំនាញ; និង ការពង្រឹងការ-

តាមដាន, ការត្រួតពិនិត្យ និងការវាយតម្លៃ លើការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រ ដែលត្រូវបានដាក់ចេញ;

(៣). **ការលើកកម្ពស់ សុខភាព និង សុខុមាលភាពប្រជាជន** ដែលមានគោលដៅយុទ្ធ-សាស្ត្រផ្តោតលើ ការបន្តកាត់បន្ថយអត្រាឈឺ និង ស្លាប់ បណ្តាលពីជំងឺមិនឆ្លងចម្បងៗ, ការបន្តលើកកម្ពស់សុខភាពបន្តពូជ សុខភាពទារក កុមារ និង មាតា, ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំបរិវត្តកម្ម និង អភិបាលកិច្ច ក្នុង វិស័យសុខាភិបាល, ការបន្តបង្កើនគុណភាព និងសមត្ថភាពរោគវិនិច្ឆ័យ ក្នុងការព្យាបាល និង ការថែទាំ, ការបន្តពង្រឹងគុណភាពនៃការបណ្តុះ-បណ្តាលវិជ្ជាជីវៈសុខាភិបាល, ការលើកកម្ពស់សមត្ថភាពជំនាញ, ការលើកកម្ពស់កិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, និង ការចូលរួមរបស់ប្រជាជនតាមសហគមន៍;

(៤). **ការពង្រឹង ប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការកសាង និង ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ និងសង្គតិភាព, ទាំងក្នុងប្រព័ន្ធជំនួយសង្គម និង ប្រព័ន្ធសន្តិសុខសង្គម, និង ការពង្រឹងប្រព័ន្ធស្បៀង ដែលផ្តល់សន្តិសុខស្បៀង និង អាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប ដោយឈរលើស្មារតី "**មិនបោះបង់ពលរដ្ឋខ្មែរណាម្នាក់**" និង ដោយគោរពតាមអភិក្រម ចំនួន ៤ គឺ:

**ទី១**.ចីរភាពនៃកម្មវិធី, **ទី២**.លទ្ធភាពអាចទ្រទ្រង់បាននៃថវិកាជាតិ, **ទី៣**.ការធានាបរិយាប័ន្ន និង សមធម៌សង្គម ដោយផ្តោតលើកិច្ចអន្តរាគមន៍របស់រដ្ឋ លើគ្រួសារក្រីក្រ គ្រួសារងាយរងគ្រោះ និង គ្រួសារងាយរងហានិភ័យ, និង **ទី៤**.ភាពអាចពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម តាមរយៈការអភិវឌ្ឍប្រព័ន្ធ; និង

(៥). **ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌, សមធម៌ និង បរិយាប័ន្ន** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការធ្វើពលកាវូបនីយកម្មពលរដ្ឋ (People Revitalization) ឱ្យមានសមត្ថភាព ផលិតភាព សីលធម៌ គុណធម៌ ចរិយា-ធម៌ ភាពអំណត់ សុចរិតភាព វិន័យ និង ការទទួលខុសត្រូវខ្ពស់, និង ការលើកកម្ពស់ស្មារតី និងមនសិការស្នេហាជាតិ ការពារជាតិ ឯកភាពជាតិ ការចេះយកអាសារគ្នា ការចែករំលែក ការចូលរួម គុណតម្លៃសង្គម និង ស្មារតីគោរពច្បាប់ ស្រឡាញ់សន្តិភាព ក៏ដូចជាស្រឡាញ់វប្បធម៌ប្រពៃណីទំនៀមទម្លាប់ អំពើល្អ និង យុត្តិធម៌ សំដៅធានាបាននូវសិនិទ្ធភាពសង្គម (Social Cohesion) និងសុខដុមរមនាសង្គម។

**បញ្ចកោណទី ២៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង ដែលក្នុងនេះ រាជរដ្ឋាភិបាលបន្តផ្តោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ ៖**

(១). **ការអភិវឌ្ឍ វិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការពង្រីក និងការធ្វើពិពិធកម្ម មូលដ្ឋានកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនតម្លៃបន្ថែមក្នុងវិស័យគន្លឹះដែលមានស្រាប់ និង ការអភិវឌ្ឍប្រភពថ្មីនៃកំណើន ដែលជាកត្តាមិនអាចខ្វះបាន ក្នុងការបង្កើនសក្តានុពលកំណើន និង ការពង្រឹងភាពធន់នឹងវិបត្តិ;

(២). **ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការបន្តកសាង និង ពង្រឹងមូលដ្ឋានគ្រឹះ និង បុរេលក្ខខណ្ឌគន្លឹះៗ សម្រាប់បង្កើនផលិតភាព, លើកកម្ពស់ភាពប្រកួតប្រជែង និង ជំរុញពិពិធកម្ម តាមរយៈការបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, និង ការកសាង និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗ;

(៣). **ការកែលម្អបរិយាកាស ធុរកិច្ច និង ការវិនិយោគ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការបន្តកែលម្អបរិយាកាសអំណោយផល ដល់ការធ្វើធុរកិច្ច, ការធ្វើពាណិជ្ជកម្ម និង ការវិនិយោគ តាមរយៈ ការសម្រួល និង ការធ្វើសាមញ្ញកម្ម នីតិវិធីពាក់ព័ន្ធនានា, ការធ្វើឌីជីថលភាវូបនីយកម្ម សម្រាប់ការផ្តល់សេវាសាធារណៈ និង កិច្ចការរដ្ឋបាល, ការពង្រឹងសមត្ថភាពស្ថាប័ន, និង ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលអន្តរក្រសួង-ស្ថាប័ន;

(៤). **ការពង្រឹង ប្រសិទ្ធភាព និង ភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម, និង តំបន់ពាណិជ្ជកម្មសេរី** (Free-Trade Zone) ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការប្រមូលផ្តុំ និង ការអភិវឌ្ឍបណ្តាញផលិតកម្ម ឱ្យដើរតួនាទីសំខាន់ ក្នុងការបង្កើនប្រសិទ្ធភាព និង ភាពប្រកួតប្រជែងនៃឧស្សាហកម្មកម្ពុជា សំដៅបង្កើនការទាក់ទាញការវិនិយោគផ្ទាល់ ពីបរទេស និង ក្នុងស្រុក, លើកកម្ពស់ផលិតកម្ម និង ការកែច្នៃ សម្រាប់នាំចេញ, និង ជាពិសេស គាំទ្រដល់ការបង្កើតការងារ និង ការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ; និង

(៥). **ការធ្វើទំនើបវាទនុវត្តន៍ យន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការរៀបចំ និង ការកែលម្អក្របខ័ណ្ឌ និង យន្តការហិរញ្ញប្បទាន, និង ការធ្វើពិពិធកម្មផលិតផល និង សេវាហិរញ្ញវត្ថុដែលធានាបានសន្ទនីយភាព (Liquidity) ក្នុងទីផ្សារ និង ជម្រើសហិរញ្ញប្បទានសម្រាប់ការវិនិយោគ សំដៅរួមចំណែកជំរុញការវិនិយោគ និង ការធ្វើពិពិធកម្មសេដ្ឋកិច្ច ។

**បញ្ហានោលណទី ៣៖ ការអភិវឌ្ឍវិស័យឯកជន និង ការងារ ដែលក្នុងនេះ រាជរដ្ឋាភិបាល បន្តផ្តោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ៖**

(១). **ការអភិវឌ្ឍទីផ្សារការងារ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការជំរុញការអភិវឌ្ឍទីផ្សារការងារ តាមរយៈការបង្កើត, ការរក្សា, និង ការបង្កើនការងារដល់កម្មករ-និយោជិត, ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ, សំដៅបង្កើនប្រាក់ចំណូល, ទ្រទ្រង់ជីវភាពសមរម្យ និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន;

(២). **ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និង មធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការបន្តជំរុញការអភិវឌ្ឍបរិយាកាសអំណោយផល ដល់សហគ្រាសធុនមីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ឱ្យរីកលូតលាស់, ធន់នឹងវិបត្តិ និង មាននវានុវត្តន៍ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និង ការបង្កើតការងារ ព្រមទាំងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្លងអន្តរកាលចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ;

(៣). **ការពង្រឹងភាពជាដៃគូ វិស័យសាធារណៈ និង វិស័យឯកជន** ដែលមានគោលដៅយុទ្ធសាស្ត្រ ផ្តោតលើការបន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដែលជាយន្តការមិនអាចខ្វះបាន និង មានប្រសិទ្ធភាព ក្នុងការគាំទ្រពិពិធកម្ម និង កំណើន, និង ការបន្តពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ចំពោះការអនុវត្តគម្រោងការវិនិ-យោគសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន;

(៤). **ការពង្រឹងការប្រកួតប្រជែង** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការបន្តជំរុញការប្រកួតប្រជែងស្មើភាព តាមរយៈការបន្តបង្កើតបរិយាកាសធ្វើធុរកិច្ចដោយស្មើភាព, គ្មានការរើសអើង, តាមនីតិវិធីដោយយុត្តិធម៌ និង ស្របតាមអភិក្រម "**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**" សំដៅរួមចំណែកដល់ការបង្កើតមុខទំនិញ និង សេវាកម្មថ្មីៗ, និង ការបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ចកម្ពុជា; និង

(៥). **ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការបន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឱ្យកាន់តែមានស័ក្តិសិទ្ធភាព, ភាពធន់នឹងវិបត្តិ, បរិយាប័ន្ន, ពិពិធភាព និង ភាពទំនើប តាមរយៈការបន្តអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត, ជំរុញភាពស៊ីជម្រៅហិរញ្ញវត្ថុ, ពង្រឹងសមត្ថភាពស្ថាប័ន និង អក្ខរកម្មហិរញ្ញវត្ថុ, និង លើកស្ទួយឌីជីថលភាវូបនីយកម្ម ក្នុងវិស័យហិរញ្ញវត្ថុ ។

**បញ្ហាគោលនយោបាយទី ៤៖** ការអភិវឌ្ឍប្រកបដោយ ភាពធន់, ចីរភាព និងបរិយាប័ន្ន ដែលក្នុងនេះ **រាជរដ្ឋាភិបាលបន្តផ្ដោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ៖**

(១). **ការធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្ដោតលើការទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមាពីផលលាភប្រជាសាស្ត្រ និង ការពង្រឹងភាពធន់ប្រជាសាស្ត្រ ដោយបន្តជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន និង លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារដឹកនាំ;

(២). **ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព** ដែលមានគោលដៅយុទ្ធសាស្ត្រផ្ដោតលើ ការអភិរក្សដើម្បីការអភិវឌ្ឍ សំដៅលើកកម្ពស់វិភាគទានកិច្ចការនេះ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និង ទេសចរណ៍, ការពង្រឹងការគ្រប់គ្រងធនធានរ៉ែ, ការធានាចីរភាពធនធានព្រៃឈើ ជលផល និង គុណភាពដី, ព្រមទាំងការការពារ ការអភិវឌ្ឍ និង ការទាញយកប្រយោជន៍ឱ្យអស់សក្ដានុពលពីបេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព;

(៣). **ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្ដោតលើការបន្តពង្រឹងតួនាទី និង ការអភិវឌ្ឍវិស័យកសិកម្មឱ្យទំនើប សម្បូរបែប និង មានភាពធន់ ដែលគាំទ្រដល់ការអភិវឌ្ឍជនបទ សំដៅធានាសន្តិសុខ និង សុវត្ថិភាពស្បៀង, បង្កើនតម្លៃបន្ថែមខ្ពស់, ជំរុញភាពប្រកួតប្រជែង, និង លើកកម្ពស់គុណភាពជីវភាពនៅជនបទ;

(៤). **ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម** ដែលមានគោលដៅយុទ្ធសាស្ត្រផ្ដោតលើការពង្រីកទីក្រុង និង ការអភិវឌ្ឍទីក្រុងថ្មីៗបន្ថែម នៅតាមបណ្ដារាជធានី-ខេត្ត, ការបង្កើតសួនសាធារណៈ និង ឧទ្យានបៃតង, និង ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម ដើម្បីធានាសុវត្ថិភាព សោភ័ណភាព បរិស្ថានល្អ និង សុខុមាលភាពសម្រាប់ការរស់នៅ និង ប្រសិទ្ធភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច; និង

(៥). **ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង** ដែលមានគោលដៅយុទ្ធសាស្ត្រផ្ដោតលើការកាត់បន្ថយជាអតិបរមានូវការបំពុល និងផលប៉ះពាល់បរិស្ថាន, ការពង្រឹងការគ្រប់គ្រងទឹក និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ, និងការចូលរួមចំណែក ក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកល ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ។

**បញ្ចកោណទី ៥៖ ការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមឌីជីថល ដែលក្នុងនេះ រាជរដ្ឋាភិបាលបន្តផ្តោតលើកិច្ចការអាទិភាព ចំនួន ៥ គឺ៖**

(១). **ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការដឹកនាំការធ្វើបរិវត្តកម្មឌីជីថល ដោយរាជរដ្ឋាភិបាលធ្វើជាគំរូ និង ជឹកមុខ ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល តាមរយៈការធ្វើឌីជីថលភាវូបនីយកម្មកិច្ចការសាធារណៈរបស់រដ្ឋ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ជូនប្រជាជន និងវិស័យឯកជន, និង ការពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ;

២). **ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការជំរុញការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច, ការបង្កើតធុរកិច្ចថ្មីឌីជីថល (Digital Startups), ការជំរុញការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស, ការជំរុញការអភិវឌ្ឍខ្សែច្រវាក់ឌីជីថល និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, និងការជំរុញការកសាង និងការអភិវឌ្ឍ ប្រព័ន្ធនវានុវត្តន៍ឌីជីថល ដើម្បីសម្រួលធុរកិច្ច និងពាណិជ្ជកម្ម សំដៅជំរុញសម្ទុះនៃកំណើនសេដ្ឋកិច្ច;

(៣). **ការកសាង និង ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការកសាង និង ការពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមមាន ការតភ្ជាប់ឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និង ក្លោដ ឬ មជ្ឈមណ្ឌលទិន្នន័យ សំដៅពង្រឹងគុណភាព និង ប្រសិទ្ធភាព នៃបណ្តាញតភ្ជាប់ឌីជីថល, ការចែករំលែកព័ត៌មាន និងការផ្តល់សេវាទូរគមនាគមន៍;

(៤). **ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើ ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល តាមរយៈ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង យន្តការស្ថាប័នសន្តិសុខ ឌីជីថល, និង ការលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឱ្យបានទូលំទូលាយ; និង

(៥). **ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ** ដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយចាប់យកកាលានុវត្តភាព និង ទាញយកអត្ថប្រយោជន៍ជាអតិបរមា ពីបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ, រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ, និងជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ។

## ៦. កម្មវិធីគោលនយោបាយអាទិភាព ទាំង ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣

ជាមួយនេះ, ក្នុងតួនាទីជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** នឹងជំរុញការអនុវត្ត**កម្មវិធីគោលនយោបាយអាទិភាព ទាំង ៦** ដែលត្រូវចាប់អនុវត្តក្នុងឆ្នាំ ២០២៣ នេះតែម្តង រួមមាន ៖

(១). ការពង្រីកសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល;

(២). ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស;

(៣). ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់ គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ, និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន;

(៤). ការដាក់ចេញ **យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ;

(៥). ការដាក់ចេញនូវយន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ; និង

(៦). ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្ម ទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស និង ការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ ។

បន្ថែមលើនេះ, រាជរដ្ឋាភិបាល បានកំណត់បញ្ហាប្រឈមជាអាទិភាពមួយចំនួន ដែលទាមទារការដាក់ចេញនូវវិធានការគន្លឹះ សម្រាប់ដោះស្រាយក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ដែលរួមមាន៖

- <u>**ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ**</u>**: ដោយផ្តោតសំខាន់លើការពង្រឹងគុណភាព, ប្រសិទ្ធភាព, និងសមិទ្ធកម្មរបស់មន្ត្រី និង ស្ថាប័ន** តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះជាក់ស្តែង រួមមាន៖ ទី ១. ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ ប្រកបដោយគុណាធិបតេយ្យ, តម្លាភាព, យុត្តិធម៌, បរិយាប័ន្ន, និង ប្រសិទ្ធភាព; ទី ២. ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ, សីលធម៌, វិជ្ជាជីវៈ,

ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព; និង ទី ៣. ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ប្រកបដោយ សង្គតិភាព, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព ។

- **ការលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាពសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យ ដល់ មធ្យមសិក្សា** តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះដាក់ស្តែង រួមមាន៖ ទី ១. ការពង្រឹងអភិបាលកិច្ចសាលា; ទី២. ការពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា, និង សកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង, វិន័យ, សីលធម៌ និងឥរិយាបថរបស់សិស្ស; ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និង ការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា; និង ទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា-អាណាព្យាបាល និង សហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក "**ភាពជាដៃគូ រដ្ឋ និង សហគមន៍ ដើម្បី ការអប់រំ**" Public-Community Partnership for Education (PCPE) ។
- **ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ដោយផ្តោតសំខាន់លើការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន** តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះដាក់ស្តែងរួមមាន ៖ ទី១. ពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដោយយកចិត្តទុកដាក់លើការពង្រាយបុគ្គលិកគ្រប់ចំនួន ដែលមានក្រមសីលធម៌ល្អ និង ទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ, ការផ្គត់ផ្គង់ឱសថ, សម្ភារបរិក្ខារ និង ការបំពាក់ឧបករណ៍ពេទ្យ, ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសុខាភិបាលឌីជីថល, ទី២. អភិវឌ្ឍសមត្ថភាពស្ថាប័នសុខាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ, ការងារនិយ័តកម្ម, ការឆ្លើយតបនឹងការគម្រាមកំហែងសុខភាពសាធារណៈ និងគ្រោះអាសន្នសុខភាព និងការផ្តល់សេវាថែទាំសុខភាពដល់ប្រជាជន ឱ្យកាន់តែមានភាពឆ្លើយតប ប្រកបដោយសមធម៌ និងគណនេយ្យភាពខ្ពស់ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចដំណើរការមុខងារស្ថាប័ន, និង ទី៣. កសាងភាពជាដៃគូរឹងមាំរវាងវិស័យសុខាភិបាលសាធារណៈ និងឯកជន ដើម្បីឱ្យប្រជាជនទទួលបានសេវាថែទាំសុខភាពមានគុណភាព, សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

- **ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយ និង ឈានទៅដល់ការលុបបំបាត់ ការជួញដូរ និង ការប្រើប្រាស់គ្រឿងញៀន នៅក្នុងសហគមន៍ ។
- **ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌** ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកិច្ចការជាអាទិភាពសំខាន់ចំនួន ៣ គឺ៖ ទី១. ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ជាពិសេស វិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន; ទី២. ការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ និង ទី៣. ការត្រួត-ពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជា លើកកម្ពស់តម្លាភាព, សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

## ៧. យន្តការសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត

ដើម្បីធានាស័ក្តិសិទ្ធិភាព និង ប្រសិទ្ធភាព ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ជាពិសេសដើម្បីធានាការចាប់ផ្តើមអនុវត្តកម្មវិធីគោលនយោបាយអាទិភាព និង វិធានការគន្លឹះ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលកំណត់យន្ត-ការជាក់ស្តែងសម្រាប់ដឹកនាំសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត ដូចខាងក្រោម៖

**១. យន្តការដឹកនាំសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីគោលនយោបាយអាទិភាព ទាំង ៦៖**

យោងលើសារៈសំខាន់ និង ភាពចាំបាច់នៃការជំរុញអនុវត្តកម្មវិធីគោលនយោបាយអាទិភាព ទាំង ៦, ខ្ញុំសូមប្រគល់ភារកិច្ចជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដឹកនាំសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់ចែង និង ដាក់ឱ្យអនុវត្ត**កម្មវិធីគោលនយោបាយអាទិភាព ទាំង ៦** នេះ, ជាបន្ទាន់ និង ជាបន្តបន្ទាប់, ឱ្យបានទាន់នៅក្នុងឆ្នាំ ២០២៣, ស្របតាមការសន្យារបស់រាជរដ្ឋា-

ភិបាល ចំពោះប្រជាពលរដ្ឋ និង ត្រូវផ្ដល់របាយការណ៍វឌ្ឍនភាពការងារពាក់ព័ន្ធនឹងចំណាត់ការនេះ ជូន **គណៈរដ្ឋមន្ត្រី** នៅក្នុង**កិច្ចប្រជុំពេញអង្គ លើកទី ២** ដែលខ្ញុំគ្រោងនឹងដឹកនាំ នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣ ។

**២. យន្តការដឹកនាំសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តវិធានការគន្លឹះ៖**

ចំពោះការអនុវត្តវិធានការគន្លឹះពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, ការលើកកម្ពស់គុណភាពអប់រំ និងការលើកកម្ពស់គុណភាពសេវាសុខាភិបាល, ខ្ញុំនឹងដឹកនាំគណៈកម្មាធិការជាតិ ដោយផ្ទាល់ ដើម្បីជំរុញការអនុវត្តវិធានការគន្លឹះនីមួយៗ ។

ចំពោះការអនុវត្តវិធានការគន្លឹះពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ ការជួញដូរ និង ការប្រើប្រាស់គ្រឿងញៀន នៅក្នុងសហគមន៍, ខ្ញុំសូមប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃ, អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង ស្ថាប័ន-អាជ្ញាធរពាក់ព័ន្ធ រៀបចំផែនការសកម្មភាពជាក់ស្ដែង ។

ចំពោះការអនុវត្តវិធានការគន្លឹះពាក់ព័ន្ធនឹងការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌, ខ្ញុំសូមប្រគល់ភារកិច្ចជូនក្រសួងយុត្តិធម៌ រៀបចំផែនការសកម្មភាពជាក់ស្ដែង ។

**៣. យន្តការដឹកនាំសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១៖**

រាជរដ្ឋាភិបាលក៏សម្រេចដាក់ចេញផងដែរ នូវយន្តការជំរុញការអនុវត្ត, យន្តការដឹកនាំសម្របសម្រួល, និង យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដោយ៖

- ប្រគល់ភារកិច្ចជូន**ទីស្ដីការគណៈរដ្ឋមន្ត្រី** ទទួលបន្ទុកជា **ស្ថាប័នសម្របសម្រួលរួម**របស់រាជរដ្ឋាភិបាល នៅក្នុងក្របខ័ណ្ឌនៃយន្តការសម្របសម្រួល តាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។ ដើម្បីសម្រេចគោលដៅនេះ, ទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំឱ្យបានឆាប់នូវលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ដើម្បីកំណត់លម្អិតនូវវិធីសាស្ត្រ, បែបបទ និង

នីតិវិធីនៃការសម្របសម្រួល ការតាមដាន ការត្រួតពិនិត្យ និង ការវាយតម្លៃ លើការអនុវត្ត**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។ និង

- ប្រគល់ភារកិច្ចជូនគណៈកម្មាធិការអន្តរក្រសួង ឬ ក្រុមប្រឹក្សា ដែលមានសមត្ថកិច្ចពាក់ព័ន្ធ ទទួលបន្ទុកសម្របសម្រួលលើការជំរុញការអនុវត្តការងារអាទិភាព ដែលមានចរិតអន្តរក្រសួង-ស្ថាប័ន ឬ អន្តរវិស័យ ។

**ឯកឧត្តម, លោកជំទាវ, ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, សមាជិក-សមាជិកា នៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមជម្រាបជូនអង្គគណៈរដ្ឋមន្ត្រី និង ជនរួមជាតិ, ជាពិសេសវិស័យឯកជន មេត្តាជ្រាបថា, ខ្ញុំនឹងដឹកនាំ **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩** ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ខាងមុខនេះ ដើម្បីស្តាប់នូវមតិយោបល់ និងសំណូមពរផ្សេងៗ ក៏ដូចជាការដាក់ចេញនូវវិធានការមុតស្រួច និង ជាក់ស្តែងមួយចំនួន ដើម្បីបន្តជំរុញគាំទ្រវិស័យឯកជន ដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច ។ ខ្ញុំសូមអំពាវនាវដល់វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ មេត្តាចូលរួមក្នុងវេទិកានេះឱ្យបានសកម្មបំផុត កុំបីអាក់ខាន ។

ខ្ញុំសូមប្រគល់ភារកិច្ចជូន**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន, វិស័យឯកជន ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំវេទិកានេះ ។

សរុបជារួម, កម្ពុជាពិតជាមានមោទនភាពខ្ពស់បំផុត ជាមួយនឹងការសម្រេចបាននូវសុខសន្តិភាពដ៏ពេញលេញ និង រឹងមាំ ក្នុងរយៈពេល ២៥ ឆ្នាំ កន្លងមក; ហើយនៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពនេះ, កម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗ មិនអាចកាត់ថ្លៃបានយ៉ាងសន្ធឹកសន្ធាប់ និង បានឆ្លងកាត់បរិវត្តកម្មសំខាន់ៗជាប្រវត្តិសាស្ត្រ ដែលបានកែលម្អជីវភាពរស់នៅរបស់ប្រជាជន និង បានលើកស្ទួយកិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត លើឆាកតំបន់ និងសកល តាមរយៈការដាក់ចេញ និង ការដឹកនាំអនុវត្តដោយជោគជ័យ នូវ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** ។

ឈរលើមូលដ្ឋាននៃសមិទ្ធផលដ៏ធំធេងទាំងនេះ, ជាមួយនឹងការសម្លឹងទៅមុខ សម្រាប់រយៈពេល ២៥ ឆ្នាំទៀត, ហើយតាមរយៈការធ្វើបទឧទ្ទេសនាមផ្ទាល់នៅទីនេះ ក៏ដូចជាការផ្សាយបន្តផ្ទាល់តាមបណ្តាញសារព័ត៌មានចេញពីទីនេះ, ខ្ញុំបានបង្ហាញជូនដល់អង្គគណៈរដ្ឋ-

មន្ត្រីរបស់យើង និង ជូនដល់សហគមន៍ជាតិ និង អន្តរជាតិ ជ្រាបនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដែលជា របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា** ។ ខ្ញុំក៏បានបង្ហាញជូននូវ **វិធានការគន្លឹះ** ដែលខ្ញុំនឹងដឹកនាំតម្រង់ទិស លើការអនុវត្ត ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់នៃការដោះស្រាយបញ្ហាប្រឈម និង ការកែទម្រង់វិស័យសំខាន់ៗ ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា យើងនឹងជម្នះបាននូវបញ្ហាប្រឈម, ឧបសគ្គ និង វិបត្តិនានា ក្នុងការដឹកនាំសង្គមជាតិកម្ពុជា លើវិថីនៃការអភិវឌ្ឍ, វឌ្ឍនភាព, និង វិបុលភាព ឱ្យកាន់តែច្រើនថ្នាក់ឡើងបន្ថែមទៀត ហើយកសាងបាននូវមូលដ្ឋានគ្រឹះប្រកបដោយភាពធន់ដ៏រឹងមាំ សម្រាប់ការឈានឡើងប្រកបដោយការជឿទុកចិត្ត ឆ្ពោះទៅសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

មុននឹងបញ្ចប់, ខ្ញុំសូមអំពាវនាវដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៅតាមបណ្តាក្រសួង-ស្ថាប័ន, កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ និង អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់, អង្គនីតិប្បញ្ញត្តិ, អង្គតុលាការ, ព្រមទាំងគ្រប់ដៃគូអភិវឌ្ឍន៍ ទាំងដៃគូទ្វេភាគី និង ពហុភាគី, វិស័យឯកជន, អង្គការមិនមែនរដ្ឋាភិបាល, ក៏ដូចជាជនរួមជាតិទាំងអស់ មេត្តាផ្តល់ការគាំទ្រពេញទំហឹង និង ចូលរួមចំណែកយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តវិធានការគោលនយោបាយ និង កម្មវិធីនានា នៅក្នុងក្របខណ្ឌនៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** នេះ ក៏ដូចជា **វិធានការគន្លឹះ** ដែលខ្ញុំបានដាក់ចេញ ។

ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** និង **វិធានការគន្លឹះ** ចាប់ពីពេលនេះ តទៅ ៕

**សូមអរគុណ** !